# សុន្ទរកថា និងរបាយការណ៍របស់
# ឯកឧត្តម ប្រាក់ សុខុន ទេសរដ្ឋមន្ត្រី
# រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦
# និងទិសដៅការងារឆ្នាំ២០១៧ របស់
# ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
# ថ្ងៃទី២៨ ខែកុម្ភៈ - ០១ ខែមីនា ឆ្នាំ២០១៧

- សូមគោរពសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពដ៏ខ្ពង់ខ្ពស់
- សូមគោរព លោកជំទាវ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិក សមាជិកា ព្រឹទ្ធសភា រដ្ឋសភា
- លោកជំទាវ ឯកឧត្តម ឯកអគ្គរាជទូត
- ឯកឧត្តម លោកជំទាវ លោក លោកស្រី តំណាងក្រសួង/ស្ថាប័ន!
- ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងអស់ ជាទីមេត្រី!

ដំបូងបង្អស់ ខ្ញុំបាទសូមសម្តែងនូវអំណរគុណដ៏ជ្រាលជ្រៅបំផុតជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអញ្ជើញជាអធិបតីដ៏ខ្ពង់ខ្ពស់បំផុតក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នារសៀលនេះ ។ វត្តមានដ៏ថ្លៃថ្លារបស់សម្តេចតេជោ គឺជាការបង្ហាញអំពីការយកចិត្តទុកដាក់ខ្ពស់បំផុតរបស់សម្តេចចំពោះការងារការបរទេស និងចំពោះមន្ត្រីការទូត មន្ត្រីរាជការ និងបុគ្គលិកក្រសួងការបរទេសទាំងមូល ។

ខ្ញុំបាទក៏សូមអរគុណផងដែរចំពោះវត្តមានរបស់ឯកឧត្តម លោកជំទាវ សមាជិក សមាជិកា រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ថ្នាក់ដឹកនាំ និងតំណាងក្រសួងស្ថាប័ននានា ដែលបានផ្តល់វត្តមានដ៏ថ្លៃថ្លានាពេលនេះ ។

ក្រសួងបានបញ្ចប់នៅរសៀលនេះ នូវការប្រជុំរយៈពេល២ថ្ងៃ ដែលជា២ថ្ងៃនៃការពិគ្រោះពិភាក្សាគ្នាដោយត្រង់ៗ ផ្លាស់ប្តូរយោបល់ មេរៀន បទពិសោធន៍ទាក់ទងនឹងការងាររបស់ក្រសួងកន្លងទៅ និងស្តាប់បទឧទ្ទេសនាមលើប្រធានបទសំខាន់ៗជាច្រើន ជាអាទិ៍ គោលការណ៍នៃការអនុវត្តចំណូលចំណាយរបស់ស្ថាប័ន យុទ្ធសាស្ត្រទាក់ទាញវិនិយោគបរទេស ការគាំពារពលករចំណាកស្រុកទៅក្រៅប្រទេសមូលដ្ឋាននៃការវិភាគសភាពការណ៍នយោបាយអន្តរជាតិ និន្នាការនិងយុទ្ធសាស្ត្រសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ព្រមទាំងវិធានការពង្រឹងការអនុវត្តន៍ច្បាប់ប្រយុទ្ធប្រឆាំងអំពើពុករលួយ ។

ខ្ញុំសូមយកឱកាសនេះ សូមថ្លែងអំណរគុណសារជាថ្មីម្តងទៀតដល់ឥស្សរជនជាវាគ្មិនទាំងអស់ចំពោះបទឧទ្ទេសនាមដ៏មានសារៈសំខាន់ ដែលបានធ្វើឲ្យថ្នាក់ដឹកនាំ មន្ត្រីការទូត និងមន្ត្រីរាជការយើងបង្កើនបានការយល់ដឹងរបស់ខ្លួន ដើម្បីលើកកំពស់ប្រសិទ្ធភាពការងារតទៅមុខនិងសម្រេចឲ្យបានជោគជ័យនូវការងារការទូតពហុវិស័យ ។

កិច្ចប្រជុំចង្អៀតរវាងថ្នាក់ដឹកនាំក្រសួង និងមន្ត្រីការទូតជាន់ខ្ពស់របស់យើងបានអនុញ្ញាតឲ្យយើងខ្ញុំរកឃើញបញ្ហា និងការប្រឈម ហើយលើកឡើងនូវដំណោះស្រាយចំពោះបញ្ហាទាំងនោះ ជាពិសេសបានជួយពង្រឹងមិត្តភាព សាមគ្គីភាព ភាពស្និទ្ធស្នាល និងភាពជាមិត្តរួមវិជ្ជាជីវៈជាមួយគ្នា ។

សូមគោរពជម្រាបសម្តេច និងអង្គសន្និបាតទាំងមូលមេត្តាជ្រាបថា ក្នុងរយៈពេលជិតមួយឆ្នាំកន្លងទៅ ការងាររបស់ក្រសួងបានផ្តោតលើកំណែទំរង់ផ្ទៃក្នុងផង និងការរៀបចំឡើងនូវបន្ទាត់នយោបាយក្រៅប្រទេសដែលមានសង្គតភាពជាមួយគោលការណ៍គ្រឹះដែលមានចែងក្នុងរដ្ឋធម្មនុញ្ញផង និងការវិវត្តជាក់ស្តែងនៃសភាពការណ៍អន្តរជាតិផង ។

ខ្ញុំបាទសូមគោរពរាយការណ៍អំពីលទ្ធផលសម្រេចបានលើការដ្ឋាននានានៃកំណែទម្រង់ផ្ទៃក្នុង។

ភ្ញៀវទាំងឡាយដែលធ្វើដំណើរចូលបរិវេណរបស់ក្រសួង ពិតជានឹងបានឃើញថា ក្រសួងកំពុងស្ថិតក្នុងការដ្ឋានដ៏ធំមួយ ។ តាមពិតមិនមែនមានតែការដ្ឋានរូបវន្តជាសំណង់ប៉ុណ្ណោះទេ គឺមានការដ្ឋានផ្សេងទៀតកំពុងតែដំណើរការពោលគឺការដ្ឋានកំណែទំរង់លើវិស័យស្ថាប័ន និងរចនាសម្ព័ន្ធធនធានមនុស្សនិងហិរញ្ញវត្ថុ ។

១. ការដ្ឋានសំណង់ ៖

មានការងារ២ កំពុងដំណើរការព្រមគ្នា គឺការជួសជុលអាគារកណ្តាលមានស្រាប់ដែលមានចំណាស់១៤ឆ្នាំហើយៗដែលមិនមានឱកាសបានទទួលការជួសជុលសោះ ។ អាគារនេះមានស្ថាបត្យកម្មប្រណិត រចនាបទសមសួនខ្លាំងណាស់ ប៉ុន្តែមកដល់សព្វថ្ងៃនេះ សំណង់នេះពិបាកឆ្លើយតបនឹងតម្រូវការការងារ និងសេវាតទៅទៀត ។ សំណង់អាគារ២ ជាស្លាបសង្ខាងនឹងមកអមអគារធំនេះ ។ ស្លាបខាងជើង នឹងផ្តល់លំហការិយាល័យបន្ថែម សម្រាប់មន្ត្រីបុគ្គលិកបំពេញការងារក្នុងផាសុខភាព និងភាពថ្លៃថ្នូ ។ ស្លាបខាងត្បូង នឹងក្លាយជាអគារនៃវិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ ។

២. កំណែទំរង់ស្ថាប័ន និងរចនាសម្ព័ន្ធ ៖

ក្រសួងបានរៀបចំរចនាសម្ព័ន្ធផ្ទៃក្នុងឡើងវិញ ដោយបង្កើតអគ្គនាយកដ្ឋានថ្មីចំនួន៤ នាយកដ្ឋានថ្មីមួយចំនួន ក្នុងនោះមាននាយកដ្ឋានកិច្ចការព្រំដែន ដែលនឹងត្រូវដើរតួជាសេនាធិការ និងជាយន្តការសម្របសម្រួលទំនាក់ទំនងរវាងក្រសួង និងអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន ។ វិទ្យាស្ថានជាតិទំនាក់ទំនងការទូត និងសិក្សាអន្តរជាតិ គឺជាស្ថាប័នថ្មីបង្កើតឡើងដើម្បីកសាង និងពង្រឹងជួរអ្នកការទូតរបស់យើងឲ្យមានវិជ្ជាជីវៈច្បាស់លាស់ពិតប្រាកដ និងបំពេញមុខងារជាតំណាងដ៏សក្តិសម និងការពារផលប្រយោជន៍ប្រទេសជាតិ និងប្រជាពលរដ្ឋយើងលើឆាកអន្តរជាតិ ។ ការកែសម្រួលទាំងនេះ គឺក្នុងគោលបំណងឆ្លើយតបនឹងវិសាលភាពថ្មីនៃការងារក្រសួងផង និងបំពេញឲ្យបានពេញលេញនូវតួនាទីរបស់ខ្លួនក្នុងការជំរុញកិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយដៃគូផង ។ ជាមួយនឹងការបង្កើត

ក្រុមការងារមួយចំនួន ដូចជាក្រុមការងារដើម្បីរៀបចំការគ្រប់គ្រងទិន្នន័យនានាដោយប្រព័ន្ធឌីជីថល ជាដើមនោះ យើងខ្ញុំក៏បានចាប់ផ្តើមពិចារណាអំពីលទ្ធភាពនៃការធ្វើសមាហរណកម្ម ក្រុមស្រាវជ្រាវ និងវិភាគព័ត៌មាន (IRAG) ចូលក្នុងក្រសួងការបរទេស ដើម្បីឲ្យក្រសួងយើងមានក្រុមពិចារណារបស់ខ្លួន ដើម្បីផ្តល់ប្រឹក្សាដល់ការងារបរទេស ។

៣. វិស័យធនធានមនុស្ស និងហិរញ្ញវត្ថុ

ខ្ញុំបាទទទួលស្គាល់ថា នេះជាការដ្ឋានដ៏ពិបាកមួយ ។ គឺជាដំណើរការផ្លាស់ប្តូរផ្នត់គំនិត ឥរិយាបថ និងរបៀបរបបការងារក្នុងក្រសួងទាំងមូល ។ ក្រសួងបង្ខំឲ្យមានតម្លាភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ ទាំងចំណាយ និងចំណូល យើងខ្ញុំបានកំណត់ឲ្យផ្អែកលើតម្លាភាពសមធម៌សមត្ថភាព និងគុណសម្បត្តិក្នុងការតែងតាំង គិតពី «យើង» ច្រើនជាងគិតពី «ខ្ញុំ» ពោលគឺគិតពីផលប្រយោជន៍សមូហភាព ផលប្រយោជន៍យើងទាំងអស់គ្នា ច្រើនជាងផលប្រយោជន៍បុគ្គល ឬក្រុមណាមួយ ។ ដើម្បីធ្វើឲ្យសម្រេចគោលបំណងនេះ គឺត្រូវបំបាត់អំពើពុករលួយ ការកេងប្រវ័ញ្ច ឬការនិយមបក្សពួក ។

ដោយមានការគាំទ្រពីសម្តេចតេជោ នាយករដ្ឋមន្ត្រី ក្រសួងបានគិតគូរដល់ជីវភាពរបស់មន្ត្រីការទូត មន្ត្រីរាជការ បុគ្គលិករបស់យើង ដើម្បីឲ្យការរស់នៅនិងបំពេញការងាររបស់គាត់មានលក្ខណៈសមរម្យ និងមិនត្រូវរំខានដោយកង្វះខាតខាងជីវភាព ។ សម្រាប់អ្នកការទូតយើងនៅបរទេស ចាប់ពីដើមឆ្នាំ២០១៧នេះទៅ យើងបានតំឡើងប្រាក់ខែ និងប្រាក់ឈ្នួលផ្ទះជូនគាត់ ហើយបានផ្តល់ឲ្យវិញនូវប្រាក់ឧបត្ថម្ភសម្រាប់សហព័ទ្ធ និងកូនក្រោមអាយុ១៨ឆ្នាំ ។ កញ្ចប់ថវិកាសម្រាប់ចំណាយទូទៅរបស់ស្ថានបេសកកម្មនានាក៏ត្រូវបានពិនិត្យ កែសំរួលស្របតាមទំហំការងារនិងលក្ខណៈដោយឡែកនៃស្ថានបេសកកម្មទាំងនោះដែរ។ នៅរដ្ឋបាលកណ្តាលវិញ និងជាលើកដំបូងបំផុត ក្រសួងបានរៀបចំរបបប្រាក់រង្វាន់លើកទឹកចិត្តប្រចាំខែ ដែលបានមកពីចំណែកមួយនៃការប្រមូលចំណូលជូនរដ្ឋយកមកបែងចែកជូនថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកទាំងអស់របស់ក្រសួង ។ ខ្ញុំបាទសូមឆ្លៀតឱកាសនេះ សូមគោរពអរគុណសម្តេចតេជោនាយករដ្ឋមន្ត្រី ដែលបានអនុញ្ញាតនិងគាំទ្រកំណែទម្រង់ទាំងនេះ និងសូមអរគុណក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលបានជួយដោះស្រាយដោយសមរម្យនូវការលំបាកខាងថវិកាកន្លងទៅ ។

- **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ក្នុងឆ្នាំ ២០១៦ កន្លងទៅ កម្ពុជាបានដំណើរការសកម្មភាពការងារដ៏មមាញឹកក្នុងការជម្រុញទំនាក់ទំនងការទូត សេដ្ឋកិច្ច និងវប្បធម៌ជាមួយប្រទេសតូចធំ ដើម្បីពង្រឹងបន្ថែមទៀតនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការលើគ្រប់វិស័យដើម្បីផលប្រយោជន៍ទៅវិញទៅមក ។

ជាមួយប្រទេសជាប់ភូមិផងរបងជាមួយ យើងបានខិតខំកសាងទំនាក់ទំនងមិត្តភាពសហប្រតិបត្តិការផង និងដោះស្រាយបញ្ហាព្រំដែនដែលនៅសេសសល់ផង ដើម្បីកសាងតំបន់ព្រំដែនទាំងនោះ ទៅជាតំបន់សន្តិភាព មិត្តភាព កិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍន៍ផង ។

ទស្សនកិច្ចផ្លូវរដ្ឋមកកម្ពុជារបស់ឯកឧត្តម ស៊ី ជិនពីង ប្រធានាធិបតីនៃសាធារណរដ្ឋប្រជាមានិតចិន គឺជាព្រឹត្តិការណ៍លេចធ្លោ និងមានសារៈសំខាន់ជាងគេបំផុតក្នុងឆ្នាំកន្លងទៅ ដែលទស្សនកិច្ចនេះបានបង្ហាញយ៉ាងច្បាស់ពីឋាមពលនៃទំនាក់ទំនងពិសេសរវាងប្រទេសយើងទាំងពីរ ដែលជាដៃគូសម្រាប់សន្តិភាព សន្តិសុខ ស្ថេរភាពក្នុងតំបន់ ឈរលើមូលដ្ឋាននៃការគោរពគ្នា គាំទ្រគ្នា និងជឿទុកចិត្តគ្នាទៅវិញទៅមក។

ការផ្លាស់ប្តូរទស្សនកិច្ចញឹកញាប់រវាងថ្នាក់ដឹកនាំកម្ពុជា និងបណ្តាប្រទេសជាមិត្ត ពិសេសទស្សនកិច្ចរបស់សម្តេចតេជោនាយករដ្ឋមន្ត្រីទៅកាន់ប្រទេសជាច្រើន និងចូលរួមព្រឹត្តិការណ៍សំខាន់ៗនៅលើលោកនោះ បានពង្រឹងបន្ថែមនូវកិច្ចសហប្រតិបត្តិការខាងនយោបាយ សេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ កៀរគរជំនួយសម្រាប់ការអភិវឌ្ឍន៍ប្រទេស និងសម្រេចកិច្ចព្រមព្រៀង និងគម្រោងសហប្រតិបត្តិការច្រើន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី និងពហុភាគី ។

- **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ថ្វីត្បិតតែមានសញ្ញាជាច្រើនដែលបានបង្ហាញឲ្យឃើញពីការបន្តនិន្នាការសំខាន់ៗនៃឆ្នាំ២០១៦កន្លងទៅក្តី ក៏ឆ្នាំ២០១៧ បើកទំព័រជាមួយនឹងភាពមិនប្រាកដប្រជាជាច្រើន។

ប្រាកដណាស់ ពិភពលោកនឹងបន្តធ្វើដំណើរនៅលើផ្លូវពហុប៉ូល នៅលើផ្លូវនៃការប្រកួតប្រជែងឥទ្ធិពលរវាងមហាអំណាចធំៗ ដែលសារៈសំខាន់ និងឥទ្ធិពល នៃទំនាក់ទំនងនោះនឹងទៅហួសពីក្របខ័ណ្ឌទ្វេភាគីទៅទៀត ។ ព្រមជាមួយនេះ Brexit សង្គ្រាមនិងជំលោះនៅមជ្ឈឹម មជ្ឈមបូព៌ា និងអាហ្វ្រិក អំពើភេរវកម្ម វិបត្តិជនភៀសខ្លួន ភាពតានតឹងនៅអ៊ឺរ៉ុបខាងកើត នៅឧបទ្វីបកូរ៉េ តំបន់សមុទ្រចិនខាងត្បូង បញ្ហាប្រែប្រួលធាតុអាកាស ។ល។ សុទ្ធសឹងជាការប្រឈមដែលយើងនឹងបន្តជួបប្រទះក្នុងឆ្នាំថ្មីនេះ ។

គឺក្នុងបរិការណ៍នេះហើយដែលយើងនឹងត្រូវបំពេញបេសកកម្មការទូតយើងសម្រាប់ឆ្នាំ២០១៧នេះ ។

សម្រាប់ស្ថានបេសកកម្ម/ស្ថានតំណាងរបស់យើងទៅក្រៅប្រទេស យើងនឹងត្រូវខិតខំធ្វើយ៉ាងណាឲ្យការងារកាន់តែមានប្រសិទ្ធភាព ហើយចាប់ដំណើរការងារការទូតពហុវិស័យរបស់យើងកាន់តែសកម្មឡើង ។

យើងនឹងជំរុញឲ្យសកម្មភាពមួយចំនួនដែលប្រទេសជាច្រើនក្នុងលោក កំពុងតែបំពេញស្រាប់ គឺលើកដំកើងមុខមាត់ប្រទេសយើងសំរាប់ជាគោលដៅនៃការវិនិយោគ និងទេសចរណ៍ ។ យើងនឹងសង្កត់ធ្ងន់លើប្រៀបខ្លាំងដែលយើងមាន ពោលគឺសំរាប់ការវិនិយោគ យើងនឹងពឹងផ្អែកលើសន្តិភាព ស្ថេរភាពនយោបាយ និងអាត្រាលូតលាស់ខាងសេដ្ឋកិច្ចលើស៧% ជាមធ្យមក្នុងរយៈពេលជាង២០ឆ្នាំកន្លងមកនេះ ភាពជាប្រទេសបើកចំហរជាងគេក្នុងចំណោមប្រទេស ASEAN មានកំលាំងពលកម្មវ័យក្មេង និងប្រាក់ឈ្នួលប្រកួតប្រជែង ។ ខាងទេសចរណ៍វិញយើងនឹងខិតខំបន្តផ្សព្វផ្សាយទាក់ទាញភ្ញៀវដោយផ្អែកលើ ភាពល្បីល្បាញនៃប្រាសាទបុរាណ រមនីយដ្ឋាន និងសម្បត្តិធម្មជាតិដ៏សំបូរនិងជា

ពិសេសការញញឹមរាក់ទាក់របស់ប្រជាពលរដ្ឋយើង ក្មេងចាស់ដែលបានធ្វើឲ្យកម្ពុជាជាប់ឈ្មោះជាប្រទេសលេខមួយក្នុងចំណោមប្រទេសដែលគួរស្រលាញ់រាប់អានជាងគេក្នុងលោក ។

ស្ថានតំណាងយើងក៏នឹងត្រូវបន្តប្រឹងប្រែងជួយការពារប្រជាពលរដ្ឋយើងរស់នៅឯក្រៅប្រទេស និងការពារផលប្រយោជន៍របស់ពួកគាត់ ជួយដល់ពលករយើងដែល ធ្វើការនៅឯនាយ ពិសេសធ្វើការដោយមិនស្របច្បាប់ និងទទួលរងគ្រោះដោយពួកមេខ្យល់ និងដោយថៅកែខ្លះ ។

- **សម្តេចតេជោ នាយករដ្ឋមន្ត្រី**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី!**

ជាថ្មីម្តងទៀតខ្ញុំសូមថ្លែងអំណរគុណដ៏ស្មោះស្ម័គ្រ និងជ្រាលជ្រៅបំផុតជូនចំពោះសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងបានគាំទ្រដល់កិច្ចប្រឹងប្រែងរបស់យើងខ្ញុំក្នុងការកែទំរង់នានា និងបានដឹកនាំវិស័យការទូតប្រកបដោយសុភវិនិច្ឆ័យ និងគតិបណ្ឌិតសំរាប់កម្ពុជាមួយឯករាជ្យ អធិបតេយ្យ សន្តិភាព អភិវឌ្ឍន៍ និងប្រកបដោយសេចក្តីថ្លៃថ្នូរ ។

ខ្ញុំក៏សូមអរគុណបណ្តាក្រសួង ស្ថាប័ន ស្ថានទូត ស្ថានបេសកកម្ម អង្គការអន្តរជាតិនានាដែលតែងផ្តល់កិច្ចសហប្រតិបត្តិការ និងការគាំទ្រដល់បេសកកម្មរបស់ក្រសួង ។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពជូនពរសម្តេច ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយស សមាជិក សមាជិកា នៃអង្គសន្និបាតទាំងមូល ទទួលបាននូវពុទ្ធិពរទាំងបួនប្រការ និងទទួលបាននូវជ័យជំនះគ្រប់ភារកិច្ច ។ ក្នុងឱកាសដ៏វិសេសវិសាលនេះ ខ្ញុំបាទសូមគោរពអញ្ជើញសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា មេត្តាមានប្រសាសន៍សំណេះសំណាល និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់ ។ សូមគោរពអញ្ជើញសម្តេច ។